**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# សារលិខិត
# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
# នៃព្រះរាជាណាចក្រកម្ពុជា
# អបអរសាទរពិធីបុណ្យសមុទ្រលើកទី៥ ក្រោមប្រធានបទ
# «ទីក្រុងបៃតង-ឆ្នេរស្អាត-សមុទ្រខៀវស្រងាត់» (Green City-Clean Beach-Blue Sea)
# ខេត្តព្រះសីហនុ ថ្ងៃទី២៣-២៥ ខែធ្នូ ឆ្នាំ២០១៦

*- ជនរួមជាតិទាំងអស់ជាទីមេត្រី !*

ក្នុងរយៈពេលប៉ុន្មានទសវត្សចុងក្រោយនេះ កម្ពុជាបានឆ្លងកាត់នូវការផ្លាស់ប្តូរយ៉ាងច្រើនទាំងក្នុងទិដ្ឋភាពនយោបាយ សន្តិសុខ សេដ្ឋកិច្ច និងសង្គម។ កម្ពុជាបានផ្លាស់ប្តូររូបភាពយ៉ាងឆាប់រហ័សពីអ្វីដែលធ្លាប់ស្គាល់ថាជាទឹកដីនៃវាលពិឃាដ និងសង្គ្រាម មកជាកម្ពុជាដែលមានសុខសន្តិភាព ស្ថិរភាពនយោបាយ សុវត្ថិភាពពេញលេញ និងការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ ព្រមទាំងបានក្លាយជាគោលដៅទេសចរណ៍លំដាប់ពិភពលោកប្រកបដោយក្តីសង្ឃឹមឆ្ពោះទៅរកអនាគតមួយដ៏រុងរឿងនិងត្រចះត្រចង់។ រាជរដ្ឋាភិបាលចាត់ទុកវិស័យទេសចរណ៍ជាវិស័យអាទិភាព ជា **«មាសបៃតង»** រួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ តាមរយៈការបង្កើត និងបង្កើនឱកាសការងារ បង្កើនប្រាក់ចំណូលជូនប្រជាពលរដ្ឋដោយផ្ទាល់និងដោយប្រយោល ជំរុញការនាំចេញនៅនឹងកន្លែង ទ្រទ្រង់កំណើនសេដ្ឋកិច្ច បង្កើនចំណូលជាតិពិសេសចូលរួមជួយដល់ការអភិរក្សវប្បធម៌ និងថែរក្សាការពារបរិស្ថាន ធនធានធម្មជាតិរបស់យើងប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់។

ជាមួយគ្នានេះ វិស័យទេសចរណ៍បាននិងកំពុងលើកកម្ពស់កិត្យានុភាពរបស់ព្រះរាជាណាចក្រកម្ពុជាលើឆាកអន្តរជាតិផងដែរ ជាក់ស្តែងក្នុងឆ្នាំ២០១៦នេះ ក្រុមប្រឹក្សាពាណិជ្ជកម្មនិងទេសចរណ៍អឺរ៉ុប បានជ្រើសរើសយកព្រះរាជាណាចក្រកម្ពុជា ជា **«គោលដៅទេសចរណ៍ល្អបំផុតលើពិភពលោកឆ្នាំ២០១៦»** និងជា **«គោលដៅវប្បធម៌ពេញនិយមក្នុងឆ្នាំ២០១៦»** ដែលនេះពិតជាបានឆ្លុះបញ្ចាំងយ៉ាងប្រត្យក្សពីសភាពការណ៍ពិតរបស់កម្ពុជានាពេលបច្ចុប្បន្ន និងអច្ឆរិយភាពរបស់កម្ពុជា ជាគោលដៅទេសចរណ៍ **«វប្បធម៌និងធម្មជាតិ»** ហើយកម្ពុជាបាននិងកំពុងក្លាយជាបេះដូងនិងជាគោលដៅទេសចរណ៍ដ៏ទាក់ទាញនៃតំបន់អាស៊ីនិងអាស៊ីអាគ្នេយ៍។ កាលពីឆ្នាំ២០១១ តំបន់**ឆ្នេរសមុទ្រកម្ពុជា** បានក្លាយជាសមាជិកក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក ហើយបាននិងកំពុងរួមចំណែកយ៉ាងសកម្មក្នុងការធ្វើឱ្យកម្ពុជាក្លាយជា

គោលដៅទេសចរណ៍ប្រកបដោយឧត្តមភាព និងប្រជាប្រិយភាពខ្ពស់ ព្រមទាំងចូលរួមចំណែកសម្រេចចក្ខុវិស័យអាស៊ានជាគោលដៅទេសចរណ៍លំដាប់ពិភពលោក និងប្រកបដោយភាពកក់ក្តៅ "ASEAN: the World-Class Destination" និង"ASEAN: Feel the Warmth"។ កត្តានេះ បានធ្វើឱ្យតំបន់ឆ្នេរកម្ពុជាដើរតួនាទីយ៉ាងសំខាន់ ក្នុងការទាក់ទាញការវិនិយោគ និងត្រូវបានចាត់ទុកជាគោលដៅទេសចរណ៍ប្រកបដោយភាពប្រកួតប្រជែងខ្ពស់នៅកម្ពុជា និងក្នុងតំបន់។

ក្នុងបរិបទនេះ ការប្រារព្ធ**ពិធីបុណ្យសមុទ្រ** មិនត្រឹមតែចូលរួមចំណែកក្នុងការផ្សព្វផ្សាយពីសក្តានុពលទេសចរណ៍នៃខេត្តតំបន់ឆ្នេរសមុទ្រប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចូលរួមគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវខ្ពស់ដោយឈរលើការប្តេជ្ញាចិត្តរួមមួយច្បាស់លាស់ក្នុងការរក្សាតុល្យភាពរវាងផលប្រយោជន៍សេដ្ឋកិច្ច សង្គម បរិស្ថាន និងវប្បធម៌ប្រជាពលរដ្ឋមូលដ្ឋាន ដូចដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈប្រធានបទនៃ **ពិធីបុណ្យសមុទ្រលើកទី៥នេះ** គឺ **«ទីក្រុងបៃតង ឆ្នេរស្អាត សមុទ្រខៀវស្រងាត់»**។ ជាក់ស្តែងតំបន់ឆ្នេរសមុទ្រទទួលបានភ្ញៀវទេសចរអន្តរជាតិប្រមាណជាង**១៥%** នៃចំនួនទេសចរសរុបមកកម្ពុជា ដែលចំណែកទីផ្សារនេះបាននិងកំពុងកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ។

ឈរលើមូលដ្ឋាននៃកំណើននេះ ក៏ទាមទារឱ្យមានការគិតគូរ និងគ្រប់គ្រងឱ្យហ្មត់ចត់ ដោយត្រូវមានផែនការអភិវឌ្ឍ និងគ្រប់គ្រងទេសចរណ៍ ពិសេសស្របពេលដែលពិភពលោកទាំងមូលបាននិងកំពុងប្រឈមនឹងការវិវត្តថ្មីៗឥតឈប់ឈរទាំងផ្នែកសេដ្ឋកិច្ច សង្គម និងបរិស្ថាន។ ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈម ការយកចិត្តទុកដាក់ដល់ទស្សនទាននៃ**ភាពស្អាត និងបៃតង** គឺពិតជាមានភាពចាំបាច់ ខណៈពេលដែលពិភពលោកកំពុងបោះជំហានទៅមុខនៅក្នុងសម័យកាលបៃតង។ ការអភិវឌ្ឍទេសចរណ៍តំបន់ឆ្នេរទាមទារចាំបាច់ឱ្យមាន **ការអភិវឌ្ឍទីក្រុងស្អាត/ទីក្រុងបៃតង ឆ្នេរស្អាតនិងកោះបៃតង** ដែលជាការគិតគូរខ្ពស់ដល់ការអភិរក្ស ថែរក្សាសម្បត្តិវប្បធម៌ ធនធានធម្មជាតិ និងបរិស្ថានប្រកបដោយនិរន្តរភាព។ ទីក្រុងជាប់ឆ្នេរគួរតែជា **ទីក្រុងបៃតង/ទីក្រុងស្អាត** មានន័យថាទីក្រុងដែលមានបរិស្ថាន អនាម័យ និងសណ្តាប់ធ្នាប់ល្អគួបផ្សំនឹងហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់គ្រប់គ្រាន់ដែលផ្តល់នូវភាពកក់ក្តៅ និងមជ្ឈដ្ឋានរស់នៅល្អប្រសើរដល់ប្រជាជន និងភ្ញៀវទេសចរ។ ការអភិវឌ្ឍ**ទីក្រុងតំបន់ឆ្នេរឱ្យក្លាយជាទីក្រុងបៃតង** មិនត្រឹមតែកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានដល់និរន្តរភាពនៃធនធានតំបន់ឆ្នេរប៉ុណ្ណោះទេ តែថែមទាំងជួយបង្កើនភាពទាក់ទាញដល់ភ្ញៀវទេសចរឱ្យមកទស្សនា និងកំសាន្តកាន់តែច្រើនថែមទៀតផង។

ក្នុងន័យនេះ យើងចាំបាច់ត្រូវ **«រួមគិត រួមធ្វើ រួមទទួលខុសត្រូវ»** ក្នុងការអភិវឌ្ឍវិស័យទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជាឱ្យមាននិរន្តរភាព ហើយទីក្រុងជាប់ឆ្នេរត្រូវតែជាជ័យលាភីទីក្រុងស្អាត និងជ័យលាភីទីក្រុងទេសចរណ៍ស្អាតអាស៊ាន ស័ក្តិសមជា **«ឆ្នេរសមុទ្រកម្ពុជា៖ តារារះនាទិសនិរតី»**។

ឆ្លៀតក្នុងឱកាសនៃពិធីដ៏វិសេសវិសាលនេះ ខ្ញុំសូមអំពាវនាវដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ បងប្អូនជនរួមជាតិទាំងអស់ វិស័យឯកជនចូលរួមឱ្យ

បានផុសផុលប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ធ្វើឱ្យពិធីបុណ្យសមុទ្រនៅឆ្នាំនេះប្រព្រឹត្តទៅប្រកបដោយភាពជោគជ័យ។ លើសពីនេះទៀត ខ្ញុំក៏សូមអំពាវនាវដល់ប្រតិបត្តិករទេសចរណ៍ ទេសចរជាតិ និងអន្តរជាតិ អាជ្ញាធរមូលដ្ឋាន និងបងប្អូនប្រជាពលរដ្ឋចូលរួមឱ្យកាន់តែសកម្មក្នុងចលនាប្រឡងប្រណាំង **«ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋាកិច្ចល្អ»** និងសហការថែរក្សាសោភ័ណភាព អនាម័យបរិស្ថាន ដែលជាកត្តាចម្បង មិនអាចខ្វះបានក្នុងការថែរក្សាតំបន់ឆ្នេរសមុទ្រឱ្យស្រស់ស្អាតគង់វង្សយូរអង្វែង ដើម្បីបន្តទុកជាមរតកដល់កូនចៅជំនាន់ក្រោយ។

ខ្ញុំមានសង្ឃឹមយ៉ាងមុតមាំថា ការប្រារព្ធពិធីបុណ្យសមុទ្រនឹងជាកាល្លានុវត្តភាពដ៏ប្រសើរថ្មីមួយសម្រាប់កម្ពុជា ក្នុងការធ្វើឱ្យឆ្នេរសមុទ្រកម្ពុជាក្លាយជាគោលដៅទេសចរណ៍ប្រកបដោយគុណភាពដែលជាកត្តាចូលរួមចំណែកការពារបរិស្ថាន ការពារធនធានធម្មជាតិ ការផ្តល់ចំណូលដោយផ្ទាល់ ការបង្កើនការងារ ការចូលរួមកាត់បន្ថយភាពក្រីក្រជូនដល់ប្រជាពលរដ្ឋក្នុងតំបន់ឆ្នេរ ពិសេសចូលរួមចំណែកធ្វើឱ្យសម្រេចបាននូវ**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០** របស់អង្គការសហប្រជាជាតិ ព្រមទាំងបង្កើនស្មារតីស្រឡាញ់ជាតិមាតុភូមិ សាមគ្គីភាព និងមិត្តភាពផងដែរ។ ខ្ញុំសូមជូនពរឱ្យ**ការប្រារព្ធពិធីបុណ្យសមុទ្រ**នាឆ្នាំ២០១៦នេះ ប្រព្រឹត្តទៅយ៉ាងអធិកអធម និងប្រកបដោយភាពសប្បាយរីករាយ៕

រាជធានីភ្នំពេញថ្ងៃទី១៤ខែធ្នូ ឆ្នាំ២០១៦

**ហ៊ុន សែន**